សមាគមនិស្សិតខ្មែរនៅប្រទេសជប៉ុន
在日カンボジア留学生協会
Cambodian Students Association in Japan

# CSAJ Essay Contest 2015

*Cambodian Students Association in Japan (CSAJ) would like to announce its annual essay contest for the year 2015. The CSAJ Essay Contest aims to engage Cambodian youth in issues of social and personal development and to allow them to express their concerns and solutions publicly.*

## We would like to hear your views on ONE of the following topics

1. Food quality in Cambodia is relatively low. According to a specialist in chemistry and food section from Royal Academy of Cambodia in 2011, food on everyday market sales are reported 41%-80% infected with toxins. From your point of view, what can be done to reduce toxicity in food in Cambodia? Who do you think should initiate the solution to this problem? Why?
2. In the last few years, Cambodia has done many reforms and the country's economy has been growing remarkably. However, most farmers are still poor. Some people say that the ASEAN Economic Integration in 2015 will make Cambodians, especially farmers face difficulties, as the agricultural sector in Cambodia is still weak. Do you think what should be done to improve the agricultural sector in order to help farmers to escape from poverty and be ready for ASEAN Economic Integration?
3. Reading is beneficial to human life in many ways. However, it is said that Cambodian people including students do not read much. How important do you think reading is? If you were able to change things, what would you do to promote "reading culture"?
4. In recent years, the Cambodian wedding ceremony has been civilized and has become a profitable business for many service providers. Not only the married couple but also their friends need to deal with financial matters. For example, the married couple save money to pay for the ceremony preparation, and friends save from salary to pay for so many wedding invitations. This is really a matter for our society. If wedding is just a symbol of tied relationship among the couple, why we need to earn hard and pay high for the wedding ceremony? Describe your viewpoints on the above matter with supporting examples.

## Awards

- 1st Prize: 200 USD, certificate & gold medal
- 2nd Prize: 150 USD, certificate & silver medal
- 3rd Prize: 100 USD, certificate & bronze medal
- 7 Finalists: 50 USD each & certificate

## Eligibility

- Hold a Cambodian nationality and is residing in Cambodia
- Not older than 23 years of age as of 15th July 2015
- Not the winners in CSAJ's previous essay contests

## Requirements

⇒ Essays must be written in either Khmer (1500-3000 words) or English (1000-2000 words); annotations will not be counted.
⇒ Essays must be type-written, double-spaced and in A4 size paper.
⇒ Essays must be the original work of the contestant. If plagiarism is found, you will be disqualified for this contest. Use of other people's works must be properly cited.
⇒ Each essay must be included full name, school or workplace, email address, and phone number of the contestant.

*Note: Your personal information will be used for this essay contest purpose only, and will not be distributed or used for any other purposes.

## Schedule

- 15th July 2015 : Submission deadline
- 1st August 2015 : Announcement of 10 finalists (CSAJ homepage and direct contact to each finalist)
- 22nd August 2015 : Final presentation and selection of 3 winners to be held in Phnom Penh.

## How to submit your essay

Please submit your essay in MS Word and PDF format via email to: essay2015@csaj-khmer.org by **15th July 2015**. Please write 'CASJ Essay Contest 2015' in the subject of your email.

## Selection process

CSAJ Essay Contest 2015 Commission will select the top ten essays for the final round based on the essay's content, style, clarity and how well you support your arguments. The jury will select three winning essays out of the top ten finalists at a final presentation session to be held on 22nd August 2015, in Phnom Penh.

For more information, please visit our website: http://essaycontest.csaj-khmer.org or contact us via email: essay2015@csaj-khmer.org or call us: (+81) 80-3696-3450 (Japan)

Copyright © 2015 by Cambodian Students Association in Japan

សមាគមនិស្សិតខ្មែរនៅប្រទេសជប៉ុន
在日カンボジア留学生協会
Cambodian Students Association in Japan

# ការប្រកួតសរសេរ អត្ថបទតែងសេចក្តី ប្រចាំឆ្នាំ២០១៥

*សមាគមនិស្សិតខ្មែរនៅប្រទេសជប៉ុន(CSAJ)សូមជូនដំណឹងដល់សាធារណជនអំពីការប្រកួតតែងអត្ថបទប្រចាំឆ្នាំ២០១៥។ ការប្រកួតនេះធ្វើឡើងជារៀងរាល់ឆ្នាំ ក្នុងគោលបំណងផ្តល់ឱកាសដល់យុវជនកម្ពុជាអាចចូលរួមចំណែកក្នុងការអភិវឌ្ឍខ្លួនឯង និងសង្គម ព្រមទាំងអាចបញ្ចេញមតិ និងដំណោះស្រាយជាសាធារណៈនូវបញ្ហាសង្គមនានា។*

## បេក្ខជន ឬបេក្ខនារីអាចជ្រើសរើសប្រធានបទមួយក្នុងចំណោមប្រធានបទទាំងប្រាំខាងក្រោម៖

1. គុណភាពអាហារនៅកម្ពុជានៅមានកម្រិតទាបនៅឡើយ។ បើយោងតាមមន្ត្រីជំនាញផ្នែកសារធាតុគីមី និងម្ហូបអាហារនៃរាជបណ្ឌិតសភាកម្ពុជា ក្នុងឆ្នាំ ២០១១ ផលិតផលម្ហូបអាហារចំនួន ៨១% ទៅ ៨0% នៅក្នុងប្រទេសកម្ពុជា មានផ្ទុកសារធាតុគីមីដែលមានគ្រោះថ្នាក់ដល់សុខភាព។ តាមយោបល់របស់អ្នក តើយើងអាចកាត់បន្ថយជាតិពុលក្នុងអាហារក្នុងប្រទេសកម្ពុជាដោយរបៀបណា? តើអ្នកណាខ្លះគួរជាអ្នកចាប់ផ្តើមក្នុងដំណើរការនេះ? ហេតុអ្វី?
2. នៅប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រទេសកម្ពុជាបានធ្វើកំណែទម្រង់ជាច្រើនហើយសេដ្ឋកិច្ចក្នុងប្រទេសក៏មានការរីកចម្រើនជាលំដាប់ដែរ ប៉ុន្តែកសិករភាគច្រើននៅតែមានជីវភាពក្រីក្រ។ មនុស្សមួយចំនួននិយាយថា ការធ្វើសមាហរណកម្មសេដ្ឋកិច្ចអាស៊ាននៅក្នុងឆ្នាំ ២០១៥នឹងធ្វើឲ្យប្រជាជនកម្ពុជា ជាពិសេសកសិករ ជួបការលំបាកដោយសារវិស័យកសិកម្មកម្ពុជានៅអន់ខ្សោយនៅឡើយ។ តើអ្នកគិតថា សកម្មភាពអ្វីខ្លះដែលត្រូវធ្វើ ដើម្បីអភិវឌ្ឍវិស័យកសិកម្ម ក្នុងគោលបំណងជួយកសិករឲ្យរួចផុតពីភាពក្រីក្រ និងរៀបចំខ្លួនជាស្រេចសម្រាប់ការធ្វើសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន?
3. ការអានផ្តល់ផលប្រយោជន៍ជាច្រើនយ៉ាងដល់ជីវិតមនុស្ស។ ប៉ុន្តែប្រជាជនខ្មែររួមទាំងសិស្ស និស្សិតផងដែរ ហាក់ដូចជាមិនសូវមានទម្លាប់អានទេ។ តើអ្នកគិតថាការអានមានសារប្រយោជន៍ដូចម្តេចខ្លះ? ប្រសិនបើអ្នកអាចផ្លាស់ប្តូរស្ថានភាពបាន តើអ្នកនឹងធ្វើអ្វីខ្លះដើម្បីលើកស្ទួយ វប្បធម៌នៃការអាននេះ?
4. ក្នុងអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ពិធីរៀបមង្គលការនៅប្រទេសកម្ពុជាមានការរីកចម្រើនគួរឲ្យកត់សំគាល់ និងជាពិសេសវាបានក្លាយជាការផ្តល់ប្រាក់ចំណេញសម្រាប់អ្នកប្រកបរបរផ្តល់សេវាកម្មផ្សេងៗក្នុងពិធីមង្គលការ។ ផ្ទុយទៅវិញ មិនត្រឹមតែគូស្វាមីភរិយាថ្មីទេ ប៉ុន្តែថែមទាំងមិត្តភក្តិរបស់ពួកគេ ត្រូវប្រឈមនឹងបញ្ហាប្រាក់កាសដែរ។ ឧទាហរណ៍ គូស្វាមីភរិយា ត្រូវសន្សំប្រាក់ដើម្បីចំណាយលើសេវាកម្មអាពាហ៍ពិពាហ៍ ចំណែកមិត្តភក្តិរបស់ពួកគេ ត្រូវសន្សំពីប្រាក់ចំណូលរបស់គេ សម្រាប់ចងដៃមង្គលការជាច្រើន។ វប្បធម៌បែបនេះគឺពិតជាបញ្ហាមួយសម្រាប់សង្គមខ្មែរយើង។ ប្រសិនបើពិធីមង្គលការគឺគ្រាន់តែចង់បញ្ជាក់អំពីសម្ព័ន្ធភាពរបស់គូស្វាមីភរិយា ហេតុអ្វីយើងត្រូវរកប្រាក់យ៉ាងលំបាកដើម្បីតែចំណាយលើពិធីរៀបអាពាហ៍ពិពាហ៍? ចូរបង្ហាញអំពីទស្សនៈរបស់អ្នក ដោយលើកឧទាហរណ៍ជាអំណះអំណាង។

## រង្វាន់

- ជ័យលាភីលេខ១៖ ទឹកប្រាក់ ២00USD មេដាយមាស និងលិខិតសរសើរ
- ជ័យលាភីលេខ២៖ ទឹកប្រាក់ ១៥0USD មេដាយប្រាក់ និងលិខិតសរសើរ
- ជ័យលាភីលេខ៣៖ ទឹកប្រាក់ ១00USD មេដាយសំរឹទ្ធិ និងលិខិតសរសើរ
- បេក្ខជនសរសេរបានល្អបន្ទាប់៧រូប៖ ទឹកប្រាក់ ៥0USD និងលិខិតសរសើរ

## លក្ខខណ្ឌនៃការចូលរួម

- មានសញ្ជាតិកម្ពុជា និងកំពុងស្នាក់នៅកម្ពុជា
- មានអាយុមិនលើសពី២៣ឆ្នាំ គិតត្រឹមថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៥
- មិនធ្លាប់ជាជ័យលាភីនៃការប្រកួតឆ្នាំមុនៗរបស់ CSAJ

## លក្ខខណ្ឌនៃការសរសេរអត្ថបទតែងសេចក្តី

⇒ អត្ថបទអាចជាភាសាខ្មែរ (១៥០០ ទៅ ៣០០០ពាក្យ) ឬជាភាសាអង់គ្លេស (១០០០ ទៅ២០០០ពាក្យ)

⇒ សរសេរដោយកុំព្យូទ័រ ដោយសរសេរមួយជួររំលងមួយជួរ (double-spaced) និងប្រើក្រដាសទំហំA4

⇒ ជាអត្ថបទផ្ទាល់ខ្លួនគ្មានការចម្លងស្នាដៃអ្នកដទៃ។ ប្រសិនបើដកស្រង់ផ្នែកណាមួយពីស្នាដៃអ្នកដទៃត្រូវមានដាក់ឯកសារយោងឲ្យបានត្រឹមត្រូវ បើពុំនោះទេអត្ថបទនោះអាចនឹងត្រូវដកចេញពីការប្រកួតនេះ

⇒ អត្ថបទត្រូវភ្ជាប់ជាមួយនូវឈ្មោះ ទីកន្លែងសិក្សាឬធ្វើការ អ៊ីមែល និងលេខទូរស័ព្ទទំនាក់ទំនង របស់បេក្ខជន ឬបេក្ខនារី *

* ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកនឹងត្រូវប្រើសម្រាប់ការប្រកួតនេះ និងមិនត្រូវបានចែកចាយ ឬប្រើក្នុងគោលបំណងផ្សេងពីនោះឡើយ។

## កាលវិភាគ

- ១៥ កក្កដា ២០១៥៖ ផុតកំណត់នៃការផ្ញើអត្ថបទ
- ០១ សីហា ២០១៥៖ ប្រកាសលទ្ធផលអ្នកជាប់វគ្គជម្រុះដំបូងចំនួន១០រូប
- ២២ សីហា ២០១៥៖ ការធ្វើបទបង្ហាញដោយអ្នកជាប់វគ្គជម្រុះទាំង១០រូប និងប្រកាសលទ្ធផលជ័យលាភី៣រូប ព្រមទាំងពិធីចែករង្វាន់នៅទីក្រុងភ្នំពេញ

## របៀបផ្ញើអត្ថបទមកចូលរួមប្រកួត

សូមផ្ញើអត្ថបទតែងសេចក្តីរបស់អ្នកជា MS Word និង PDF format មកកាន់អ៊ីមែល៖ essay2015@csaj-khmer.org យ៉ាងយូរបំផុតត្រឹម**ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៥**។ នៅពេលផ្ញើសូមសរសេរ "CSAJ Essay Contest 2015" នៅត្រង់ Subject នៃអ៊ីមែលរបស់អ្នក។

## ដំណាក់កាលនៃការជ្រើសរើស

អត្ថបទល្អជាងគេចំនួន១០នឹងត្រូវបានជ្រើសរើសដោយផ្អែកលើខ្លឹមសារ រចនាបថ ភាពច្បាស់លាស់នៃតែងសេចក្តី និងការផ្តល់អំណះអំណាងគាំទ្រមតិរបស់ខ្លួន។ ក្នុងនោះ អត្ថបទចំនួន៣នឹងត្រូវបានជ្រើសរើសចុងក្រោយជាជ័យលាភីប្រចាំឆ្នាំ២០១៥ ដោយគណៈកម្មាការ នៅភ្នំពេញ ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៥។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ : http://essaycontest.csaj-khmer.org ឬទាក់ទងមកកាន់យើងខ្ញុំតាមរយៈ អ៊ីមែល: essay2015@csaj-khmer.org ឬ ទូរស័ព្ទ: (+81) 80-3696-3450 (ជប៉ុន)

រក្សាសិទ្ធិ © ២០១៥ ដោយសមាគមនិស្សិតខ្មែរនៅប្រទេសជប៉ុន